
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 2.11 អាហារនៅក្នុងទីរហោស្ថាន

ព្រះបានបង្គាប់លោកម៉ូសេ និងអើរ៉ុនជាបងប្រុសរបស់គាត់ឲ្យទៅស្រុកអេស៊ីព្ទ ហើយជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលពីស្តេចផារ៉ោន ដែលបានធ្វើបាបពួកគេយ៉ាងខ្លាំង ។ ក្រោយពីមានបណ្តាសាជាច្រើនបានដាក់លើ ស្តេចផារ៉ោន និងជនជាតិអេស៊ីព្ទ ។ ជនជាតិអ៊ីស្រាអែលបានត្រូវអនុញ្ញាត ឲ្យចាកចេញពីស្រុកអេស៊ីព្ទ ។ ព្រះបានសន្យាថានឹងមានទឹកដីថ្មីសម្រាប់ពួកគេគឺទឹកដីកាណាន ។

ទោះបីជាជនជាតិអ៊ីស្រាអែលបានអរព្រះគុណ ដែលពួកគេបានចាកចេញពីប្រទេសអេហ្ស៊ីព្ទ ជាជីវិតដ៏លំបាកក៏ដោយមិនយូរប៉ុន្មានពួកគេចាប់ផ្តើមត្អូញត្អែរនឹងលោកម៉ូសេ និងអើរ៉ុន ។ ហេតុអ្វីបានជាព្រះអម្ចាស់មិនឲ្យយើងស្លាប់នៅស្រុកអេស៊ីព្ទទៅ ជាកន្លែងដែលយើងមានសាច់ និងនំប៉័ងឆ្អាញ់បរិភោគ? ព្រះអង្គបាននាំយើងខ្ញុំទៅកាន់វាលរហោស្ថាន ជាកន្លែងដែលយើងនឹងត្រូវអត់ឃ្លានស្លាប់» ។

ព្រះទ្រង់បានប្រាប់លោកម៉ូសេថា៖ «អញនឹងបង្អុរភ្លៀងជានំប៉័ងចុះពីលើមេឃមកឲ្យឯងរាល់គ្នា ។ ប្រជាជននឹងត្រូវចេញទៅក្រៅរាល់ថ្ងៃ ហើយប្រមូលចំណែកមកដើម្បីបរិភោគ ។ អញនឹងល្បងលពួកគេមើលថា តើពួកគេនឹងគោរពតាមបញ្ញត្តិរបស់អញដែរឬទេ ។ នៅថ្ងៃទីប្រាំមួយនៃសប្តាហ៍ពួកគេនឹងឃើញថាពួកគេមានអាហារគ្រប់គ្រាន់សម្រាប់រយៈពេលពីរថ្ងៃ ។ នៅថ្ងៃទីប្រាំពីរពួកគេគួរតែសម្រាក" ។

នៅព្រឹកបន្ទាប់ប្រជាជនបានរកឃើញបំណែកគ្រាប់ល្អិតៗ ដែលមើលទៅដូចទឹកសន្សើមកកនៅលើដី ។ ពួកគេនិយាយគ្នាថា "នោះជាអ្វី?" អាហារនោះត្រូវបានគេហៅថា "នំម៉ាណា" ដែលជាភាសារបស់ពួកគេដែលមានន័យថា "តើវាជាអ្វី?" លោកម៉ូសេបានប្រាប់ពួកគេថា នេះជានំប៉័ងដែលព្រះបានឲ្យ ពួកគេបរិភោគ ។

ជនជាតិអ៊ីស្រាអែលត្រូវបានប្រាប់ពីបរិមាណត្រឹមត្រូវ នៃនំម៉ាណាសម្រាប់មនុស្សម្នាក់ៗ ។ អ្នកដែលធ្វើតាមការណែនាំមានអាហារហូបគ្រប់គ្រាន់ហើយពួកគេពេញចិត្ត ។ អ្នកដែលមិនស្តាប់លោកម៉ូសេ ហើយបានយកលើសពីអ្វីដែលពួកគេគួរតែយក បានរកឃើញថានៅព្រឹកបន្ទាប់នំម៉ាណារបស់ពួកគេ មានដង្កូវនៅក្នុងនោះហើយវាទៅជាស្អុយរលួយ ។ ហើយអស់អ្នកដែលចេញទៅរកនំម៉ាណានៅថ្ងៃទីប្រាំពីរពួកគេរកមិនឃើញសោះ ។ ពួកគេត្រូវរៀនធ្វើតាមអ្វី ដែលព្រះបានមានបន្ទូល ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលថា "ឃើញទេ? តើត្រូវចំណាយពេលប៉ុន្មាន ដើម្បីរៀនច្បាប់ទាំងនេះ? នៅថ្ងៃទីប្រាំមួយត្រូវយកអ្វីដែលអ្នកត្រូវការរយៈពេលពីរថ្ងៃ ។ សម្រាកនៅថ្ងៃទីប្រាំពីរ" ។ ជនជាតិអ៊ីស្រាអែលមិនចូលចិត្តធ្វើតាមច្បាប់ហើយពួកគេចូលចិត្តត្អូញត្អែរ។ ក្រោយមកប្រជាជនបានធុញទ្រាន់ នឹងការបរិភោគតែនំប៉័ង ហើយត្អូញត្អែរដាក់លោកម៉ូសេ ។ បន្ទាប់មកព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរប្រាប់ប្រជាជនថា "នៅពេលល្ងាចអ្នកនឹងបរិភោគសាច់ ។ នៅពេលព្រឹកអ្នកនឹងបរិភោគនំប៉័ង ។ "នៅយប់នោះសត្វបក្សីតូចៗដែលគេហៅថា "សត្វក្រួច" បានហោះចូលជំរំរបស់ពួកគេ ។ មនុស្សគ្រប់រូបមានសាច់បរិភោគគ្រប់គ្រាន់ ។

ជនជាតិអ៊ីស្រាអែលបរិភោគនំម៉ាណាអស់រយៈពេលសែសិបឆ្នាំ ពេលពួកគេធ្វើដំណើរនៅវាលរហោស្ថាន ។ ព្រះទ្រង់បានប្រទាននំម៉ាណា និងសត្វក្រួចសម្រាប់ពួកគេរាល់ថ្ងៃ ។ ពួកគេមិនចាំបាច់ព្រួយបារម្ភទេ ។ ពួកគេមានអាហារ រហូតដល់ពួកគេទៅដល់ព្រំប្រទល់ស្រុកកាណាន ជាទឹកដីដែលព្រះទ្រង់បានសន្យាជាមួយពួកគេ ។

**(និក្ខមនំ ១៦)**

## 2.11 អាហារនៅក្នុងទីរហោស្ថាន - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

### កំណាត់ចំណាំ

១) លោកម៉ូសេ និងលោកអើរ៉ុនបានរំដោះជនជាតិអ៊ីស្រាអែល ពីស្តេចផារ៉ោននៅស្រុកអេស៊ីព្ទ ។ ព្រះទ្រង់បានប្រាប់លោកម៉ូសេឲ្យនាំយកជនជាតិអ៊ីស្រាអែល ទៅស្រុកកាណានជាទឹកដីដែលព្រះបានសន្យា ។

២) ប្រជាជនអ៊ីស្រាអែលបានត្អូញត្អែរថា ពួកគេមិនមានអាហារបរិភោគទេ ។ ពួកគេបាននិយាយទៅកាន់លោកម៉ូសេថា «ហេតុអ្វីបានជាអ្នកមិនអនុញ្ញាត ឱ្យពួកយើងស្លាប់នៅស្រុកអេស៊ីព្ទទៅ ។ យើងមានអាហារ ឆ្ងាញ់ៗ ដើម្បីបរិភោគនៅទីនោះ» ។

៣) ព្រះអម្ចាស់បានប្រទានស្បៀងអាហារ ទៅឲ្យជនជាតិអ៊ីស្រាអែល ។ ទ្រង់បានប្រទាននំប៉ុងនៅពេលព្រឹក ប្រជាជនហៅថា "នំម៉ាណា" និងបក្សីតូចៗដែលគេហៅថា "សត្វក្រួច" នៅពេលល្ងាច ។ ព្រះក៏បានប្រទានការណែនាំអំពីរបៀបប្រមូលអាហារសម្រាប់រាល់ថ្ងៃ ។

៤) អ្នកខ្លះក៏បានធ្វើតាម ខ្លះទៀតមិនបានធ្វើតាមទេ ។ អ្នកដែលធ្វើតាមការណែនាំ មានអាហារហូបគ្រប់ គ្រាន់ ។ អ្នកដែលប្រមូលអាហារលើស បានរកឃើញថាវាមានដង្កូវ និងស្អុយរលួយនៅថ្ងៃបន្ទាប់ ។

៥) ព្រះទ្រង់បានប្រទានអាហារនេះ ដល់ជនជាតិអ៊ីស្រាអែល អស់រយៈពេលសែសិបឆ្នាំ ។ ពួកគេបានបរិភោគនំម៉ាណា រហូតដល់ពួកគេទៅដល់ព្រំដែនស្រុកកាណាន ដែលជាទឹកដីដែលព្រះបានសន្យាជាមួយពួកគេ ។

**សំណួរ:**

១) តើទឹកដីអ្វី ដែលព្រះទ្រង់បានប្រាប់ដល់លោកម៉ូសេ ឲ្យនាំយកជនជាតិអ៊ីស្រាអែលចេញទៅ?

២) តើប្រជាជនចាប់ផ្តើមត្អូញត្អែរអំពីអ្វី?

៣) តើព្រះទ្រង់បានប្រទានអាហារអ្វីខ្លះ ទៅដល់ជនជាតិអ៊ីស្រាអែល?

៤) តើមានអ្វីកើតឡើងចំពោះអាហារនៅសល់ ដែលមនុស្សបានយក?

៥) តើព្រះបានប្រទានអាហារនេះដល់ពួកគេ ដល់ពេលណា?

**ចម្លើយ:**

១) ព្រះបានប្រាប់ដល់លោកម៉ូសេ ឲ្យនាំជនជាតិអ៊ីស្រាអែលទៅកាន់ទឹកដីកាណាន ។

២) ប្រជាជនត្អូញត្អែរថា ពួកគេគ្មានអាហារសម្រាប់បរិភោគ ។

៣) ព្រះបានប្រទានសត្វស្លាបតូចៗ ដែលគេហៅថាសត្វក្រួច ។ ទ្រង់ក៏បានប្រទាននំប៉ុង ដែលប្រជាជនហៅថា "នំម៉ាណា" ។

៤) នៅថ្ងៃបន្ទាប់អាហារដែលនៅសល់ នឹងមានដង្កូវនៅក្នុងវា ហើយស្អុយរលួយ ។

៥) ព្រះអម្ចាស់ទ្រង់ប្រទានស្បៀងអាហារដល់ពួកគេ អស់រយៈពេលសែសិបឆ្នាំ រហូតដល់ពួកគេទៅដល់ព្រំប្រទល់ស្រុកកាណាន ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org